**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៥

*នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ**

*-បានទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី*

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០២លើក*

*-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់* **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហមុនី** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*

*-អញ្ជើញចូលរួមក្នុងពិធីពន្លត់ភ្លើងជ័យ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកាក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់* **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហមុនី** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*

*-អញ្ជើញជូនព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេច* **ព្រះនរោត្តម សីហមុនី** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គស្តេចយាងបំពេញព្រះរាជទស្សនកិច្ចនៅសាធារណរដ្ឋបារាំង*

*-អនុញ្ញាតឲ្យឯកឧត្តម* Laszlo KOVER *ប្រធានរដ្ឋសភាប្រទេសហុងគ្រី ចូលជួបសម្តែងការគួរសម និងធ្វើសវនាការ*

*-អនុញ្ញាតឲ្យឯកឧត្តម* Nuttavudh Photisaro *ឯកអគ្គរាជទូតវិសាមញ្ញ និងពេញ*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

សមត្ថភាព នៃព្រះរាជាណាចក្រថៃ ចូលជួបសម្តែងការគួរសម

-អញ្ជើញចុះពិនិត្យស្រែស្រូវ និងសាកសួរសុខទុក្ខ សំណេះសំណាលជាមួយមន្ត្រី អាជ្ញាធរ និងប្រជាពលរដ្ឋនៅភូមិឃ្មួញ សង្កាត់ឃ្មួញ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-អញ្ជើញចុះសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋក្នុងភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-បានដង្ហែអង្គកឋិនទៅវេរប្រគេនព្រះសង្ឃ ដែលគង់ចាំព្រះវស្សាអស់ត្រីមាសក្នុងពុទ្ធសីមា នៅវត្តឧត្តមសាមគ្គីរតនារាម (ហៅវត្តហ្វាំង) ស្ថិតនៅភូមិហ្វាំង ឃុំបានប៉ុង ស្រុកវើនសៃ ខេត្តរតនគិរី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០០ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា ប្អាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមក្នុងពិធីពន្លត់ភ្លើងជ័យ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកាក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងសួរសុខទុក្ខគ្រួសារយោធិនពិការ ៣១៧គ្រួសារ នៅតាកែនកោះស្លា និងចូលរួមបើកបវេស្សនកាលឆ្នាំសិក្សា ២០១៥-២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** នៅឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត និងចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋ នៅខេត្តកំពត

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធដល់ប្រជាជនបារាំង ដែលស្លាប់ដោយ

គេរវកម្ម នៅទីក្រុងប៉ារីស កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅស្ថានទូតបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៧ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជាអធិបតីបើក-បិទវេទិកាថ្នាក់ស្រុកភូមិភាគ៣ស្តីពី ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការពង្រឹងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំក្នុងការអភិវឌ្ឍមូលដ្ឋាន ដោយជានាសមភាពយេនឌ័រ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៤៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៣០ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើកដើម្បី៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០៣ និងសេចក្តីស្នើច្បាប់ចំនួន០២ ទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា៖

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៤ ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជា

ណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៤.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៥.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ ស្តីពីវិសោធនកម្មមាត្រា២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា

៦.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំវិសាមញ្ញចំនួន០២លើកដើម្បីៈ**

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់

៣.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៤.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ស្តីពីការជំរុញ និងការការពារ ទៅវិញទៅមកនៃវិនិយោគ

៥.ពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មមាត្រា២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា

**៤. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែវិច្ឆិកានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

### ៤.១. មុខងារនីតិកម្ម

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខី ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ចំនួន០៥។

### ៤.២. មុខងារតំណាង

-បានទទួលពាក្យបណ្តឹងបានចំនួន១៣ករណី ផ្ញើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន១៣ករណី ទទួលលិខិតឆ្លើយតបពីក្រសួងយុត្តិធម៌ចំនួន០១ករណី សាលាខេត្តសៀមរាបចំនួន០១ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន១២ករណី។

-រៀបចំវេទិកាថ្នាក់ស្រុកស្តីពី "ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ក្នុងការអភិវឌ្ឍមូលដ្ឋាន ដោយជានាសមភាពយេនឌ័រ" នៅឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-រៀបចំបទបង្ហាញស្តីពីហេដ្ឋារចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដល់សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME) ខេត្តបាត់ដំបងចំនួន១៥នាក់ ដែលបានមកទស្សនកិច្ចសិក្សានៅព្រឹទ្ធសភា

-រៀបចំកិច្ចពិគ្រោះយោបល់ស្តីពី " បញ្ហាពាក់ព័ន្ធនឹងគ្រឿងស្រវឹង ការប្រឈម និងដំណោះស្រាយ " ក្រោមការជួយឧបត្ថម្ភគាំទ្រពីអង្គការអន្តរជាតិ (IOGT) និងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព(PDP)

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំងចុះទៅពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋ នៅឃុំព្រៃស្នៀត ស្រុកពារាំង ខេត្តព្រៃវែង

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ៨ ប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥កំណត់កាលបរិច្ឆេទរៀបចំវេទិកា នៅខេត្តកំពង់ធំ និងពិនិត្យពិភាក្សាផែនការប្រតិបត្តិរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ឆ្នាំ២០១៦

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ប្រជុំដើម្បីរៀបចំចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន នៅខេត្តព្រះសីហនុ

-ប្រជុំត្រៀមលក្ខណៈ និងពិភាក្សាបន្ថែមលើប្រធានបទសំខាន់ៗដែលនឹងត្រូវ

អញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំសភានិយាយភាសាបារាំង(APF) ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី៧ នៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ចូលរួមជាវាគ្មិនក្នុងអង្គសិក្ខាសាលាស្តីពី " សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅកម្ពុជា" ដែលរៀបចំដោយគណៈកម្មាធិការសិទ្ធិមនុស្ស សហការជាមួយស្ថានទូតស៊ុយអ៊ែតប្រចាំកម្ពុជា

-ចូលរួមស្តាប់បទបង្ហាញលោកស្រីតំណាងអង្គការសហប្រជាជាតិនៅកម្ពុជាស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងផែនការសកម្មភាពក្រោយឆ្នាំ២០១៥ និងបទបង្ហាញរបស់វិទ្យាស្ថានកម្ពុជា ស្តីពីជនជាតិដើមភាគតិច

-ចូលរួមសន្និសីទតស៊ូមតិថ្នាក់ជាតិលើកទី៩ ស្តីពីការរួមគ្នាដើម្បីលើកកម្ពស់គណនេយ្យភាពសង្គម លើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា

-ជួបពិភាក្សាការងារជាមួយលោក **តឹមយាត ដារ៉ារិទ្ធ** នាយកប្រតិបត្តិវិទ្យាស្ថានសភាកម្ពុជា ស្តីពីការរៀបចំការិយាល័យថវិកា (PBO) និងអ្នកនិពន្ធនាយកទស្សនាវដ្តី B2B

-ជួបជាមួយលោកស្រីបណ្ឌិត Heidi Merk អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាអតីតសមាជិកព្រឹទ្ធសភារបស់សហព័ន្ធអាល្លឺម៉ង់ ដើម្បីពិភាក្សាស្វែងយល់ឲ្យបានច្បាស់អំពីតម្រូវការរបស់ព្រឹទ្ធសភា ការផ្តល់សេវាជូនព្រឹទ្ធសភាឲ្យបានល្អប្រសើរ និងដំណើរការនៃការកសាងច្បាប់

-អញ្ជើញជាគណៈអធិបតីជាមួយអង្គការសង្គមស៊ីវិលចំនួន២០អង្គការ ដើម្បីចូលរួមចែករំលែកគ្នាអំពីសកម្មភាពរកជំនួយមនុស្សធម៌មកជួយប្រទេសកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១២២លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤២លើក។

**៤.៣. មុខងារត្រួតពិនិត្យ**

-ជួបសវនាការជាមួយថ្នាក់ដឹកនាំក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដើម្បីស្ដាប់របាយការណ៍សំខាន់ជាសមត្ថកិច្ចរបស់ក្រសួងដែលអនុវត្តកន្លងមក នៅទីស្ដីការក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ។

**៤.៤. មុខងារព័ត៌មាន**

-អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ វឌ្ឍនភាពសំខាន់ បញ្ហាប្រឈមនានា ដែលពាក់ព័ន្ធទៅនឹងវិស័យ អប់រំ ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍ នៅខេត្តបាត់ដំបង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ។

-អញ្ជើញចុះបេសកកម្មស្វែងរកព័ត៌មានស្ដីពីការអនុវត្ត និងត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ នៅខេត្តរតនគិរី

-អញ្ជើញដឹកនាំក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួន១៥០នាក់ ចុះទៅទស្សនកិច្ចសិក្សា និងស្ដាប់បទបង្ហាញពីក្រុមហ៊ុនCP នៅខេត្តកំពង់ស្ពឺ និងបន្តដំណើរទៅរោងចក្រថាមពលវារីអគ្គិសនីកំចាយ នៅខេត្តកំពត

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម ***ជា ជេដ្ឋ***, ឯកឧត្តម ***អ៊ុក ប៊ុនឈឿន***, ឯកឧត្តម ***ឈួន ឡេង***,ឯកឧត្តម ***ម៉ែន ស៊ីផាន់*** និងលោកជំទាវ ***លី នារី*** បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សាស្វែងយល់បទពិសោធន៍ស្ដីអំពីសារពើពន្ធនៅតាមសមូហភាពដែនដី និងទំនាក់ទំនងសមូហភាពដែនដី និងរដ្ឋ នៅសាធារណរដ្ឋបារាំង និងប្រទេសប៊ែលហ្ស៊ិក

-ឯកឧត្តម ***ឈិត គឹមយាត*** បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កិច្ចការសង្គម និងវប្បធម៌ និងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ របស់សភាតំបន់អាស៊ី (APA) នៅទីក្រុងតេអេរ៉ង់ ប្រទេសអ៊ីរ៉ង់

-ឯកឧត្តម ***ឡាវ ម៉េងឃីន*** បានអញ្ជើញចូលរួមសន្និសីទអន្តរអាស៊ាន-ចិន (អាស៊ានបូកមួយ ) លើកទី១០ ស្ដីពីមិត្តភាពប្រជាជនអាស៊ាន-ចិន និងទទួលទង់ជាតិពីប្រទេសប៊្រុយណេ នៅរាជធានីបានដាស៊ិរីបឺហ្គាវ៉ាន់ ដើម្បីកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទអន្តរជាតិអាស៊ានបូកមួយ លើកទី១១ នាឆ្នាំ២០១៧ ចូលរួមវេទិកាអន្តរជាតិ ទីក្រុងប៉េកាំង

ឆ្នាំ២០១៩ ស្តីពីមិត្តភាពប្រជាជន ដើម្បីប្រជាជន និងដំណើរទេសចរណ៍ទៅកាន់ខេត្តទ្បានីង នៃសាធារណរដ្ឋប្រជាមានិតចិន។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩

ជ.ប្រធានព្រឹទ្ធសភា
អនុប្រធានទី២

ទេព ងន

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ